00636082

E15

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ~~00២/១៣-0៦-២00៩-អ.វ.ត.ក-អជសអ~~ 002/19.09.2007-ECCC/TC

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន: ----------------

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់ អៀង សារី សុំកុំអោយចាប់ផ្តើមថេរវេលាសម្រាប់បញ្ហាអញ្ញត្រកម្ម រហូតដល់ពេលដែលអង្គបុរេជំនុំជម្រះ បានផ្តល់នូវសំអាងហេតុនៅលើសាលដីកា របស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹង អំពីអញ្ញត្រកម្ម តាមវិធាន ៨៩**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ផ្ញើជូន៖</u> |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

**ឯកសារដើម**
**DOCUMENT RECEIVED/DOCUMENT REÇU**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 17 / 01 / 2011
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមដាក់សំណើជាបន្ទាន់របស់ អៀង សារី សុំកុំអោយចាប់ផ្តើមថេរវេលាសម្រាប់បញ្ហាអញ្ញត្រកម្ម រហូតដល់ពេលដែលអង្គបុរេជំនុំជម្រះ បានផ្តល់នូវសំអាងហេតុទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[1] និងសំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹងអំពីអញ្ញត្រកម្ម តាមវិធាន ៨៩ ។ សំណើសុំដែលថាកុំអោយចាប់ផ្តើមរាប់ថេរវេលារហូតដល់ពេលមានសំអាងហេតុគឺមានលក្ខណៈចាំបាច់ ព្រោះថាមេធាវីការពារក្តីមិនអាចកំណត់ថាបញ្ហាអញ្ញត្រកម្មណាមួយ នឹងត្រូវលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ លុះត្រាតែមេធាវីការពារក្តី បានទទួល និងបានវិភាគនូវសំអាងហេតុថា ហេតុអ្វីអង្គបុរេជំនុំជម្រះច្រានចោលនូវការតតាំងនឹងបញ្ហាយុត្តាធិការទាំងនេះ។ សំណើសុំបន្ថែមពេលវេលា និងទំព័រដែលមានជាធរមាន ដើម្បីលើកបញ្ហាអញ្ញត្រកម្ម គឺចាំបាច់ព្រោះថា មានបញ្ហាយុត្តាធិការស្មុគស្មាញជាច្រើន ដែលមេធាវីការពារក្តីទំនងជានឹងលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ បញ្ហាទាំងនេះមិនអាចដោះស្រាយអោយបានគ្រប់គ្រាន់នៅក្នុងរយៈពេលត្រឹមតែ ៣០ថ្ងៃ និងត្រឹមកម្រិត ១៥ទំព័របានឡើយ។ សំណើសុំទាំងនេះគឺមានលក្ខណៈចាំបាច់ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំកិច្ចការពារក្តីរបស់ខ្លួន ។

## I. សាវតារ

១. កាលពីថ្ងៃទី ១៦ កញ្ញា ២០១០ កសចស បានចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២[2]។

២. កាលពីថ្ងៃទី ១៧ កញ្ញា ២០១០ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍[3]

---

[1] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ មករា ២០១១ ឯកសារលេខ D427/1/26, ERN: 00634887-00634891។

[2] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស, ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ កញ្ញា ២០១០ ឯកសារលេខ D427, ERN: 00604508-00605246។

ហើយក៏បានដាក់សំណើសុំបន្ថែមចំនួនទំព័រកំណត់ដើម្បីប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយ[4]។

៣. កាលពីថ្ងៃទី ១ តុលា ២០១០ សំណើសុំនេះត្រូវបានទទួលយកដោយអង្គបុរេជំនុំជម្រះ[5]។ អង្គបុរេជំនុំជម្រះ បានថ្លែងថា "អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហាចំនួន ៧ ដែលបានលើកឡើងថា ជាបញ្ហាយុត្តាធិការ ដែលដើមបណ្តឹងឧទ្ធរណ៍ស្វះស្វែងដើម្បីប្តឹងតវ៉ានេះ បង្កើតបានជាកាលៈទេសៈពិសេស ដែលមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងអនុញ្ញាតអោយមានការបន្ថែមចំនួនទំព័របាន ... អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា វាជាផលប្រយោជន៍របស់ត្រូវចោទ ក្នុងការទទួលបាននូវដំណោះស្រាយលើបញ្ហាយុត្តាធិការទាំងនេះ<u>អោយបានពេញលេញ និងទូលំទូលាយតាមដែលអាចធ្វើទៅបាន</u>..." [6]។

៤. កាលពីថ្ងៃទី ២៥ តុលា ២០១០ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[7] ដែលមានមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ចំនួន ១១ ហើយដែលបញ្ហានីមួយៗទាក់ទងនឹងយុត្តាធិការរបស់ អវតក ។

៥. កាលពីថ្ងៃទី ១៣ មករា ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ បដិសេធចោលនូវមូលដ្ឋានមួយចំនួននៃបណ្តឹងឧទ្ធរណ៍ ហើយទទួលយកនូវមូលដ្ឋានមួយចំនួននៃបណ្តឹងឧទ្ធរណ៍។ សាលដីកាត្រូវបានចេញដោយសំអាងហេតុ "នឹងត្រូវ

---

[3] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥), ការចុះបណ្តឹងឧទ្ធរណ៍របស់មេធាវីរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២០ កញ្ញា ២០១០ ឯកសារលេខ D427/1 ។

[4] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥), សំណើជាបន្ទាន់របស់លោក អៀង សារី សុំបន្ថែមចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ទៅនឹងបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៧ កញ្ញា ២០១០ ឯកសារលេខ D427/1/1 ។

[5] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥), សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ អៀង សារី សុំបង្កើនចំនួនសន្លឹកកំណត់ ដើម្បីប្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១ ខែ តុលា ឆ្នាំ២០១០ D427/1/3, ERN:00611380-00611383, នៅកថាខណ្ឌទី ៨-១១ ។

[6] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១០-១១ (គូសបញ្ជាក់បន្ថែម) ។

[7] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ តុលា ២០១០ ឯកសារលេខ D427/1/6, ERN: 00617486-00617631។

ផ្តល់ជូនក្នុងពេលវេលាសមរម្យ"[8]។

## II. ចម្លើយតប

៦. មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងថា:

សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះ ជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថា គ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង <u>សិទ្ធិមានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន</u> សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និង សិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក[9] ។

៧. មាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក ចែងថា:

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា សមស្របតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ...ខ) <u>មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសរើសដោយខ្លួនឯង</u>...[10]។

៨. មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា:

នៅក្នុងការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនជាប់គ្រប់រូបមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ... ខ) មានពេលវេលា និង

---

[8] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ មករា ២០១១ ឯកសារលេខ D427/1/26, ERN: 00634887-00634891ទំព័រ ៥។

[9] បញ្ជាក់បន្ថែម ។

[10] បញ្ជាក់បន្ថែម ។

លក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសរើសដោយខ្លួនឯង... ។

៩. មាត្រា ១១(១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា: "ជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាថាគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់សម្រាប់ការរៀបចំការពារខ្លួន"។

## III. សំណើសុំកុំអោយចាប់ផ្តើមថេរវេលាសម្រាប់បញ្ហាអញ្ញត្រកម្ម រហូតដល់ពេលដែលអង្គបុរេជំនុំជម្រះ បានផ្តល់នូវសំអាងហេតុនៅលើសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ

១០. អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយសំអាងហេតុ "នឹងត្រូវផ្តល់ជូនក្នុងពេលវេលាសមរម្យ" [11]។ មេធាវីការពារក្តីមិនទាន់ដឹងនៅឡើយអំពី សំអាងហេតុដែលអង្គបុរេជំនុំជម្រះច្រានចោលការតតាំងនឹងបញ្ហាយុត្តាធិការ ដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ហេតុដូច្នេះ មេធាវីការពារក្តី មិនអាចដឹងថាតើត្រូវទទួលយកឬយ៉ាងណាទៅលើសំអាងហេតុរបស់ អង្គបុរេជំនុំជម្រះ ឬថាតើមានសំអាងហេតុដែលមានសុពលភាពមួយដើម្បីនឹងលើកឡើងនូវការតតាំងនឹងបញ្ហាយុត្តាធិការទាំងនេះទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែរឬទេ។ មេធាវីការពារក្តីនឹងមិនអាចបំពេញកិច្ចការប្រកបដោយវីរិយភាពទេ បើសិនជាមេធាវីការពារក្តីគ្រាន់តែដាក់បណ្តឹងឡើងវិញទៅអង្គជំនុំជម្រះសាលាដំបូង នូវបញ្ហាអញ្ញត្រកម្មដដែលៗដែលខ្លួនបានដាក់កាលពីលើកមុននៅចំពោះមុខអង្គបុរេជំនុំជម្រះនោះ។ ផ្ទុយទៅវិញ មេធាវីការពារក្តីត្រូវតែវិភាគលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ និងឆ្លើយតបទៅលើការភ័ន្តច្រលំក្នុងការវិភាគនានា ដែលអាចមាន។ បញ្ហាអញ្ញត្រកម្មដែលមានសុពលភាព និងត្រឹមត្រូវពិតជាមិនអាចធ្វើឡើងបានឡើយ លុះត្រាតែមេធាវីការពារក្តី ទទួលបាននូវសំអាងហេតុរបស់អង្គបុរេជំនុំជម្រះសិន។ វានឹងជាការរំលោភបំពានលើ

---

[11] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ មករា ២០១១ ឯកសារលេខ D427/1/26, ERN: 00634887-00634891ទំព័រ ៤។

00636087



សិទ្ធិជាសារវន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដើម្បីត្រៀមរៀបចំកិច្ចការពារក្តីរបស់ខ្លួន ដែលតម្រូវអោយលោក អៀង សារី លើកបញ្ហាអញ្ញត្រកម្មដោយមិនដឹងថាហេតុអ្វីបញ្ហាអញ្ញត្រកម្មទាំងនេះមិនត្រូវបានទទួលយកដោយអង្គបុរេជំនុំជម្រះ។

## IV. សំណើសុំពេលវេលាបន្ថែម ដើម្បីដាក់បណ្តឹងអំពីអញ្ញត្រកម្ម តាមវិធាន ៨៩

១១. វិធាន ៨៩ នៃវិធានផ្ទៃក្នុង (“វិធាន”) ចែងថា៖ “អញ្ញត្រកម្មទាក់ទងនឹង៖ ក) យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ខ) ការរលត់បណ្តឹងអាជ្ញា គ) មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ ត្រូវលើកឡើងយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចទទួលយកបានឡើយ” [12] ។ ប៉ុន្តែ វិធាន ៣៩(៤)(ក) ចែងថា “តាមរយៈពេលពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច៖ ក- ពន្យាពេលវេលាកំណត់ ដែលខ្លួនបានសម្រេច” ។

១២. មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូង សូមពន្យាពេលកំណត់ដែលនៅជាធរមាន ស្របតាមវិធាន៣៩(៤)(ក) ដោយនឹងមិនត្រូវចាប់គិតឡើយលុះត្រាតែអង្គបុរេជំនុំជម្រះបានផ្តល់នូវសំអាងហេតុ ។

១៣. ថ្វីបើ មេធាវីការពារក្តីមិនអាចធ្វើការកំណត់ជាចុងក្រោយលុះត្រាតែខ្លួនទទួលបាននូវសំអាងហេតុរបស់អង្គបុរេជំនុំជម្រះក៏ដោយ មេធាវីការពារក្តីរំពឹងថានឹងលើកឡើងនូវបញ្ហាអញ្ញត្រកម្មក្នុងទំហំដ៏ធំធេង តតាំងនឹងបញ្ហាយុត្តាធិការរបស់ អវតក។ មានបញ្ហាជាសារវន្តជាច្រើនត្រូវតែបានដោះស្រាយ ដូចជាអានុភាពនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសដែលត្រូវបានផ្តល់ជូនលោក អៀង សារី ប្រកបដោយសុពលភាព, អានុភាពនៃ*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* ទៅលើការចោទប្រកាន់បច្ចុប្បន្ន, បញ្ហាថាតើ អវតក មានយុត្តាធិការដើម្បីប្រើប្រាស់បទល្មើសអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិដែរ ឬទេ, និងបញ្ហាថាតើ អវតក មានយុត្តាធិការប្រើប្រាស់បទល្មើសជាតិ ឬបទល្មើសអន្តរជាតិ

---

[12] បញ្ជាក់បន្ថែម ។

ដែរឬទេ។ ខណៈដែលវាអាចមានលទ្ធភាពសម្រាប់ មេធាវីការពារក្ដីក្នុងការធ្វើការស្រាវជ្រាវទៅលើបញ្ហាទាំងនេះនៅមុនពេលដីកាដំណោះស្រាយចូលជាធរមាន ប៉ុន្តែវាមិនអាចទៅរួចឡើយលុះត្រាតែក្រោយពេលដែលដីកាដំណោះស្រាយចូលជាធរមានសិន ទើបមេធាវីការពារក្ដីដឹងថាសំណុំរឿងនឹងត្រូវបញ្ជូនទៅជំនុំជម្រះ ហើយបានដឹងថាបញ្ហាណាមួយត្រូវតែលើកជាអញ្ញត្រកម្មនោះ ។

១៤. បញ្ហាយុត្តាធិការ ឬបញ្ហាដទៃផ្សេងទៀត ដែលអាចរំលត់បណ្ដឹងអាជ្ញា គឺជាបញ្ហាស្មុគស្មាញដែលត្រូវការពេលវេលាពេញលេញ និងសមរម្យ ដើម្បីលើកឡើងពីបញ្ហាទាំងនេះ[13] ។ អញ្ញត្រកម្មទាំងនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការពារសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ដើម្បីទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយប្រសិនបើទទួលបានជោគជ័យ សំណុំរឿងរបស់លោក អៀង សារី ប្រហែលជាមិនបញ្ជូនទៅជំនុំជម្រះទៀតផង ឬ អាចបញ្ជូនទៅជំនុំជម្រះតែក្នុងមូលដ្ឋានកម្រិតមួយតិចតួចប៉ុណ្ណោះ ។ ហេតុដូច្នេះ វាមានសារៈសំខាន់ខ្លាំងណាស់ដែលអញ្ញត្រកម្មទាំងនេះត្រូវតែបានតាក់តែងឡើងយ៉ាងប្រុងប្រយ័ត្ន និង ពេញលេញបរិបូរ។

១៥. ប្រសិនបើមេធាវីការពារក្ដី ត្រូវជួយអង្គជំនុំជម្រះសាលាដំបូងឲ្យបានច្រើនជាអតិបរិមាក្នុងការបំពេញភាពព្រលាំផ្នែកច្បាប់ទាក់ទងនឹងបញ្ហាពាក់ព័ន្ធនានា ហើយប្រសិនបើមេធាវីការពារក្ដី ត្រូវការពារសិទ្ធិលោក អៀង សារី ដោយយកចិត្តទុកដាក់អស់ពីចិត្ត(វីរិយភាព)មែននោះ អញ្ចឹងពេលវេលាគ្រប់គ្រាន់ត្រូវតែបានគេផ្ដល់ជូន មេធាវីការពារក្ដីដើម្បីត្រៀមរៀបចំបញ្ហាអញ្ញត្រកម្មទាំងនេះ។ រយៈពេល៣០ថ្ងៃ គឺមិនគ្រប់គ្រាន់ឡើយ ជាពិសេសបើគិតពីពេលវេលាជាច្រើនដែលត្រូវចំណាយលើការបកប្រែឯកសារ ។ មេធាវីការពារក្ដីស្នើសុំដោយក្ដីគោរពដើម្បីអនុញ្ញាតអោយខ្លួនដាក់បញ្ហាអញ្ញត្រកម្មទាំងអស់តាមវិធាន៨៩ នៅក្នុងរយៈពេល៦០ថ្ងៃគិតចាប់ពីថ្ងៃដែលគេបានផ្ដល់នូវសំអាងហេតុទាំងឡាយ ដែលមានក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះទៅលើបណ្ដឹងឧទ្ធរណ៍

[13] អង្គបុរេជំនុំជម្រះកាលពីលើកមុនបានទទួលស្គាល់ថាបញ្ហានេះ គឺស្មុគស្មាញ និងអាចបង្កើតជាកាលៈទេសៈពិសេស ។ សូមមើល*ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៧៥), សេចក្ដីសម្រេចលើសំណើជាបន្ទាន់របស់ អៀង សារី សុំបង្កើនចំនួនសន្លឹកកំណត់ ដើម្បីប្ដឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១ ខែ តុលា ឆ្នាំ២០១០ D427/1/3, ERN:00611380-00611383, នៅកថាខណ្ឌទី១០ ។

របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ។

**V. សំណើសុំបង្កើនចំនួនសន្លឹកទំព័រ ដើម្បីដាក់អញ្ញត្រកម្មតាមវិធាន៨៩**

១៦. អនុលោមតាមមាត្រា៥.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក "ឯកសារដាក់នៅ...អង្គជំនុំជម្រះសាលាដំបូង មិនត្រូវលើសពី១៥ ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ៣០ទំព័រជាភាសាខ្មែរ លើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អវតក ឬសេចក្តីណែនាំអនុវត្តនេះ ឬបទបញ្ជាចេញដោយ អវតក"។ អនុលោមតាមមាត្រា៥.៤ "តាមការស្នើសុំរបស់ភាគីចូលរួម សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលពាក់ព័ន្ធអាចបង្កើនចំនួនសន្លឹករបស់ ឯកសារនៅក្នុងកាលៈទេសៈពិសេស"។

១៧. មេធាវីការពារក្តីស្នើដោយក្តីគោរពសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្កើនចំនួនសន្លឹក ដើម្បីដាក់អញ្ញត្រកម្មតាមវិធាន៨៩ អនុលោមតាមមាត្រា៥.៤ ។ បញ្ហាយុត្តាធិការ និងបញ្ហាដទៃទៀតដែលតម្រូវឱ្យមានការរំលត់បណ្តឹងអាជ្ញា គឺជាបញ្ហាស្មុគស្មាញពិបាកដោះស្រាយតាមរយៈពាក្យសុំដែលមានតែ១៥ទំព័រ ។ បញ្ហាទាំងនេះ ត្រូវតែបានដោះស្រាយឱ្យបានសមស្របដើម្បីការពារសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ។ បញ្ហាទាំងនេះ គឺជាបញ្ហាសំខាន់បំផុតដែលបានលើកឡើងដំបូងគេបង្អស់នៅអង្គជំនុំជម្រះសាលាដំបូង ។ អង្គជំនុំជម្រះសាលាដំបូង នឹងទទួលបានប្រយោជន៍ពីការពិភាក្សាពេលលេញមួយទាក់ទងនឹងបញ្ហានីមួយៗ។ អង្គបុរេជំនុំជម្រះ បានទទួលស្គាល់ពីលើកមុនថាបញ្ហាបែបនេះ គឺមានលក្ខណៈស្មុគស្មាញ ហើយចាំបាច់ត្រូវតែមានការបន្ថែមចំនួនសន្លឹកទំព័រដើម្បីវិវឌ្ឍអោយបានពេញលេញ ។ មេធាវីការពារក្តី សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើតាមការអនុវត្តរបស់អង្គបុរេជំនុំជម្រះ ហើយបង្កើនចំនួនសន្លឹកទំព័រកំណត់ជាធរមានរហូតដល់ ៤៥ ទំព័រ សម្រាប់បញ្ហាអញ្ញត្រកម្មនីមួយៗតាមវិធាន៨៩ ។

**អាស្រ័យលើមូលហេតុដូចដែលបានគូសបញ្ជាក់នៅក្នុងសំណើនេះ** មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង**បន្ថែម**ពេលវេលាកំណត់ជាធរមាន ដើម្បីដាក់អញ្ញត្រកម្មតាមវិធាន៨៩ រហូតដល់៦០ថ្ងៃ

00636090

E15

~~០០២/១៣-០១-២០១១-អ.វ.ត.ក-អជសម~~
០០២/១៩-០៩-២០០៧-អវតក/អជសដ.

គិតចាប់ពីថ្ងៃដែលគេបានផ្តល់នូវសំអាងហេតុទាំងឡាយ ដែលមានក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និង**បង្កើន**ចំនួនសន្លឹកទំព័រកំណត់ជាធរមានរហូតដល់៤៥ សន្លឹក សម្រាប់បញ្ហាអញ្ញត្រកម្មនីមួយៗ ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

**ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**